ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧ អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងការិយាល័យអាស៊ាន និងការិយាល័យស្តង់ដារឧស្សាហកម្ម ទៅជា នាយកដ្ឋានសហប្រតិបត្តិការ និងការងារអាស៊ាន និងជា នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ បក ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីស្តង់ដារឧស្សាហកម្មកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ស ំ រ េ ច

**មាត្រា១.-**

ត្រូវបានតម្លើងការិយាល័យអាស៊ាន នៃនាយកដ្ឋានកិច្ចការឧស្សាហកម្ម និងការិយាល័យស្តង់ដារឧស្សាហកម្ម នៃនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ទៅជានាយកដ្ឋានសហប្រតិបត្តិការ និងការងារអាស៊ាន និងជានាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា ចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា២.-**

នាយកដ្ឋានសហប្រតិបត្តិការ និងការងារអាស៊ានមាន តួនាទី និងភារកិច្ចដូចខាងក្រោម :

-លើកផែនការសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ និងការងារអាស៊ានពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល តាមគោលការណ៍របស់រាជរដ្ឋាភិបាល

-រៀបចំសំណុំលិខិតផ្សេងៗ សំរាប់ចរចា និងចុះហត្ថលេខា : កំណត់ហេតុ អនុស្សរណៈពិធីសារ និងកិច្ចព្រមព្រៀង

-តាមដានការអនុវត្តន៏ខ្លឹមសារក្នុងកំណត់ហេតុ អនុស្សរណៈ ពិធីសារ និងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខា

-សហការជាមួយនាយកដ្ឋានជំនាញ ក្នុងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ និងជាមួយលេខាធិការដ្ឋានអាស៊ាន លើការងារសហប្រតិបត្តិការ

-លើកគំរោងចំណាយប្រចាំឆ្នាំសំរាប់កិច្ចដំណើរការសហប្រតិបត្តិការ និងការងារអាស៊ាន

-រៀបចំកិច្ចប្រជុំ និងឯកសារពាក់ព័ន្ធការងារសហប្រតិបត្តិការ និងការងារអាស៊ាន

-បូកសរុបលទ្ធផលការងារសហប្រតិបត្តិការ និងការងារអាស៊ាន ។

**មាត្រា៣.-**

នាយកដ្ឋានសហប្រតិបត្តិការ និងការងារអាស៊ាន ត្រូវបានដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៤.-**

នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា មានតួនាទី និងភារកិច្ចដូចខាងក្រោម:

-ជំរុញការអនុវត្តន៍បច្ចេកទេសវិទ្យាសាស្ត្រជឿនលឿន សំរាប់អភិវឌ្ឍវិស័យឧស្សាហកម្ម

-គ្រប់គ្រងស្តង់ដារូបនីយកម្ម លើផលិតផល និងប្រព័ន្ធគ្រប់គ្រងនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសឧស្សាហកម្ម

-ត្រួតពិនិត្យស្តង់ដារផលិតផលឧស្សាហកម្ម និងលើកទិសដៅបង្កើនគុណភាព និង ធានាសុវត្ថិភាព

-គ្រប់គ្រងមន្ទីរពិសោធន៍ផ្នែកស្តង់ដារ ធ្វើតេស្ត និងចេញលិខិតបញ្ជាក់អំពីលទ្ធផល នៃការធ្វើតេស្តផលិតផល សំភារៈ សារធាតុទាំងឡាយ និងអំពីស្តង់ដារប្រើប្រាស់សារធាតុគីមី ក្នុងវិស័យឧស្សាហកម្ម

-បណ្តុះបណ្តាលអំពីស្តង់ដារូបនីយកម្ម ក្នុងវិស័យឧស្សាហកម្ម

-សហប្រតិបត្តិការជាមួយអង្គភាពស្តង់ដារបរទេស តំបន់ និងអង្គការអន្តរជាតិខាងស្តង់ដារូប-នីយកម្ម ដើម្បីអភិវឌ្ឍស្តង់ដារឧស្សាហកម្មកម្ពុជា

-គ្រប់គ្រង និង បញ្ជត្តិលើសញ្ញាផ្លូតក្នុងវិស័យឧស្សាហកម្ម ។

**មាត្រា៥.-**

នាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា ត្រូវបានដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា៦.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការនិងការងារអាស៊ាន និងនាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០២

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

ស៊ុយ សែម

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៨
-ឯកសារ-កាលប្បវត្តិ